ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងព្រហ្មទណ្ឌ

លេខ : ៣៨

ចុះថ្ងៃទី០១ ០៧ ៩៧

សាលដីកា

លេខ : ៣១

ចុះថ្ងៃទី៣០ ០៥ ២០០១

# តាងនាមប្រជារាស្ត្រខ្មែរ

## តុ លា កា រ កំ ពូ ល

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០១ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅ :

១ - ឯកឧត្តម ឃឹម ប៉ុណ្ណ ប្រធាន

២ - លោក ឃឹម ស៊ីផល ចៅក្រមរបាយការណ៍

៣ - លោក ទៀង មួន ចៅក្រម

៤ - លោក ស៊ិន ឌឹម ចៅក្រម

៥ - លោក យស់ សូខេរិន ចៅក្រម

លោក យាង ស្រ៊ុន ក្រឡាបញ្ជី

តំណាងមហាអយ្យការ

លោក ទីប៉ន ហោរទ្វីន ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខលេខ ១៣៨ ចុះថ្ងៃទី ២៣ - ៥ - ៩៧ របស់ឈ្មោះ ហុង គី និង បណ្តឹងសាទុក្ខលេខ ១៥១ ចុះថ្ងៃទី០៥ - ០៦ - ៩៧ របស់ឈ្មោះ ឃុំ សុវណ្ណរិទ្ធ តវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ ១០៨ ចុះថ្ងៃទី ២៣ - ៥ - ៩៧ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល និង សំណុំរឿងព្រហ្មទណ្ឌលេខ ៣៨ ចុះថ្ងៃទី ០១ ០៧ ៩៧ របស់តុលាការកំពូល ។

- ជនជាប់ចោទឈ្មោះចាន់ រតនា ហៅស្រី ឆេង ភេទប្រុស អាយុ ៣២ ឆ្នាំ ជាតិខ្មែរ កើតនៅភូមិដំណាក់ស្លូង ឃុំ ទត្តគ ស្រុក សង្កែ ខេត្ត បាត់ដំបង អតីតទំបន្ទ្រីថ្នាក់ទីពីរ មុខរបរសិប្ប ទីលំនៅបច្ចុប្បន្នភូមិទី២ ឃុំ កំពង់ស្វាយ ស្រុកសេរីសោភ័ណ ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះជ័យ លោម "ល" ម្តាយឈ្មោះ ហុង គី "ន" នៅរស់ ទោសពីមុនគ្មាន នៅក្រៅឃុំ ។

- ត្រូវចោទពីបទ: បង្កអគ្គិភ័យ ដោយចេតនា ប្រព្រឹត្តនៅភូមិទី២ ឃុំកំពង់ស្វាយ ស្រុក សេរីសោភ័ណ ខេត្ត បន្ទាយមានជ័យ កាលពីថ្ងៃទី០៣ - ៥ - ៩៥ ។

- មេធាវី គ្មាន

- អ្នកទទួលខុសត្រូវខាងសំណងរដ្ឋប្បវេណីឈ្មោះ ហុង គី "ជាម្ចាស់បណ្តឹងសាទុក្ខ" និង ជាម្តាយជនជាប់ចោទ អាយុ៥៧ ឆ្នាំ ជាតិខ្មែរ របររកស៊ីនៅផ្ទះ មានទីលំនៅភូមិទី ២ ឃុំ កំពង់ស្វាយ ស្រុកសេរីសោភ័ណ ខេត្ត បន្ទាយមានជ័យ ។

- ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ ឃុំ សុវណ្ណរិទ្ធ "ជាម្ចាស់បណ្ដឹងហៅទុក" ភេទ ប្រុស អាយុ ៣៨ ឆ្នាំ ជាតិខ្មែរ មុខរបរ ធ្វើការនៅមន្ទីរសុខាភិបាល ខេត្តបន្ទាយមានជ័យ មានទីលំនៅផ្ទះលេខ ៦៦៦ ផ្លូវលេខ ៦៨ ឃុំ កំពង់ស្វាយ ស្រុកសេរីសោភ័ណ ខេត្តបន្ទាយមានជ័យ ប្រពន្ធឈ្មោះ ចាន់ ចាន់សោភា ។

- មេធាវី គ្មាន

- តាមពាក្យបណ្ដឹងចុះថ្ងៃទី០៤-៥-៨៥ របស់ឈ្មោះ ចាន់ ចាន់សោភា ប្ដឹងពីជនល្មើសមិនស្គាល់មុខ ដែលបានលួចដុតផ្ទះខ្លួនដោយហេតុថា កាលពីថ្ងៃទី០៣-៥-៨៥ វេលាម៉ោងប្រហែល៨ ម៉ោង៥០នាទី នៅពេលខ្លួននិងប្ដីខ្លួនមិននៅផ្ទះ ឈ្មោះ ចាន់ រតនា បានមកតាមខ្លួនហើយប្រាប់ថា ភ្លើងឆេះផ្ទះខ្លួនអស់ហើយ ។

- បានឃើញសេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការអមតុលាការខេត្តបន្ទាយមានជ័យ សំរេចថា: ១- ចោទប្រកាន់ឈ្មោះចាន់ រតនា ហៅ ណាង ភេទស្រី អាយុ ១៦ ឆ្នាំ ពីបទ: បង្កអគ្គីភ័យដោយចេតនា ប្រព្រឹត្តកាលពីថ្ងៃទី០៣-០៥-៨៥ នៅក្រុមទី២ ភូមិ២ ឃុំកំពង់ស្វាយ ស្រុកសេរីសោភ័ណ ខេត្ត បន្ទាយមានជ័យ ។

បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្ដន្ទាទោសតាមមាត្រា ៥៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលចុះថ្ងៃទី ១០-០៥-១៩៨២ ។ការប្ដឹងចោទប្រកាន់ថាមានការទំលោភលើលំនៅដ្ឋាន:និងការប្ដឹងពីបទបរិហារកេរ្តិ៍ ត្រូវផ្ដិតនៅក្នុងការស៊ើបអង្កេត ។

២- បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ ៥២ ចុះថ្ងៃទី១៥-០៥-១៩៨៥ ជូនលោកចៅក្រមស៊ើបអង្កេត ដើម្បីចាត់ការជំនុំជំរះ ។

- បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ៣៤ ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ ១៩៨៥ របស់តុលាការខេត្ត បន្ទាយមានជ័យ ដែលមានខ្លឹមសារសេចក្ដីសំរេចដូចតទៅ :

១- ផ្ដន្ទាទោសលើឈ្មោះចាន់ រតនា ហៅស្រី ណាង ភេទស្រី អាយុ ១៦ ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០២ ខែ គិតពីថ្ងៃនេះតទៅ ពីបទបង្កអគ្គីភ័យដោយចេតនា ប្រព្រឹត្តនៅភូមិ២ ឃុំ កំពង់ស្វាយ ស្រុកសេរីសោភ័ណ ខេត្ត បន្ទាយមានជ័យ កាលពីថ្ងៃទី០៣-៥-៨៥ ។

២- បង្គាប់អោយឈ្មោះហុង គី ជាម្ដាយរបស់ជនល្មើសឈ្មោះចាន់ រតនា ហៅស្រីណាង ជួសជុលការអន្តរាយដល់ជនរងគ្រោះ និង ជាដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះចាន់ ចាន់សោភា ជាប្រាក់ចំនួន ២.០០០.០០០ រៀល ពីរលាន គិតពីថ្ងៃដែលសាលក្រមមានអានុភាពអនុវត្តតទៅ បើដើមបណ្ដឹងទាមទារហើយពីរនេះបដិសេធ ។ បើឈ្មោះហុង គី នឹងនៅតែមិនព្រមបង់ប្រាក់នេះទេអោយដាក់គុកបង្ខំដល់រូបកាយតាមច្បាប់កំណត់ ។ តាមមាត្រា៧ នៃច្បាប់ស្ដីពីការដាក់គុកបង្ខំដល់រូបកាយក្នុងរឿងព្រហ្មទណ្ឌ ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ១៧ក្រ ចុះថ្ងៃទី០៧-០២-៨២ ។

បទល្មើសព្រហ្មទណ្ឌដែលមានចែងអោយផ្ដន្ទាទោសតាមមាត្រា ៥៣ និងមាត្រា ៦៨ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០-៥-៨២ ។

៣- សាលក្រមនេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទ និង ដើមបណ្ដឹងរដ្ឋប្បវេណី ដោយបើកផ្លូវឧទ្ធរណ៍កំណត់ ០៤ ខែគិតពីថ្ងៃនេះតទៅ ។

- បានឃើញបណ្តឹងឧទ្ធរណ៍លេខ ០៦ ចុះថ្ងៃទី ៤ - ១០ - ១៩៥៥ របស់ឈ្មោះ ប៊ុង ឌី ដែលប្តឹងតវ៉ាពីសាលក្រមព្រហ្មទណ្ឌលេខ ៣៤ ចុះថ្ងៃទី០៣ -១០ -៥៥ របស់តុលាការ ខេត្ត បន្ទាយមានជ័យ លើសេចក្តីសំរេចទាំងមូល ។

- បានឃើញបណ្តឹងឧទ្ធរណ៍លេខ១០៨ ចុះថ្ងៃទី២៣ -១១ -៥៥ របស់ឈ្មោះចាន់ សោភា ដែលប្តឹងតវ៉ាពីសាលក្រមព្រហ្មទណ្ឌលេខ ៣៤ ចុះថ្ងៃទី០៣ -១០ -៥៥ របស់តុលាការ ខេត្ត បន្ទាយមានជ័យ លើសេចក្តីសំរេចទាំងមូល ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងរាជអាជ្ញាការអមសាលាឧទ្ធរណ៍សំរេច :

១ - ទទួលបណ្តឹងឧទ្ធរណ៍របស់ឈ្មោះប៊ុង ឌី អ្នកទទួលខុសត្រូវសំណងរដ្ឋប្បវេណី ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ។

២ - កែប្រែសាលក្រមតុលាការខេត្ត បន្ទាយមានជ័យលេខ៣៤ ចុះថ្ងៃទី០៣ -១០ -៥៥ ដោយបដិសេធ សេចក្តីក្នុងចំណុចទី ២ អនុញ្ញាតិអោយដាក់គុកបង្ខំសងទំរូបការទោស ក្រៅពីនេះតម្កល់ ។

- បានឃើញសាលដីកាព្រហ្មទណ្ឌលេខ ១០៨ ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ១៩៥៧ របស់សាលាឧទ្ធរណ៍ដែលមានខ្លឹមសារសេចក្តីសំរេចដូចតទៅ :

១ - ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ២៤ -១១ - ១៩៥៥ របស់ជនរងគ្រោះ ឈ្មោះ ចាន់ ចាន់សោភា ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែលើកចោលដោយគ្មានមូលនិង គតិច្បាប់ ។

២ - ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៣ -១០ - ១៩៥៥ របស់អ្នកទទួលខុសត្រូវ សំណងរដ្ឋប្បវេណីឈ្មោះ ប៊ុង ឌី ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ។

៣ - តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៣៤ ចុះថ្ងៃទី ៣ - ១០ -១៩៥៥ របស់តុលាការ ខេត្ត បន្ទាយមានជ័យ ទុកជាបានការ លើកលែងតែចំណុចទី១ និងទី២ ត្រូវកែប្រែ ។

៤ - ផ្តន្ទាទោសលើឈ្មោះចាន់ រតនា ពៅប្រុស ណង ភេទប្រុស អាយុ១៦ ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ១ ឆ្នាំ តែទោសនេះត្រូវព្យួរ ដោយកំណត់ពេលរយៈពេល ៥ ឆ្នាំ ចាប់គិតពីថ្ងៃដែលសាលដីកានេះចូលជាស្ថាពរ ពីបទបង្ករគ្រោះថ្នាក់ដោយ ធ្វេសប្រហែស នាំអោយគេរបួស ... ខេត្តបន្ទាយមានជ័យ កាល ពីថ្ងៃទី ០៣ - ៩ - ១៩៥៥ ។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៤៣ ២៨ និង៣០ ច្បាប់ព្រហ្មទណ្ឌស្តីពីចរាចរណ៍ចុះថ្ងៃទី ១០ កញ្ញា ឆ្នាំ ១៩៥២ ។

៥ - បង្គាប់អោយឈ្មោះប៊ុង ឌី ជាអ្នកទទួលខុសត្រូវលើសំណងរដ្ឋប្បវេណី សងការ ខូចខាតចំនួនពីរលានរៀល ២.០០០.០០០ ៛ "ដល់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះចាន់ចាន់ សោភា នៅពេលដែលសាលដីកានេះចូលជាស្ថាពរ ។ តំរូវពាក្យលើសពីនេះបដិសេធចោល ។

៦ - សាលដីកានេះកំណុំនិងប្រកាសអោយបានអានចំពោះមុខជនជាប់ចោទ និងកំឡាំងមុខដើមបណ្តឹងរដ្ឋប្បវេណីទាំងពីរ ព្រោះ សំរេចបើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

- បានឃើញបណ្តឹងសាទុក្ខលេខ ១៧៨ ចុះថ្ងៃទី ២៣-៥-១៩៧៧ របស់ឈ្មោះ ចុង គី ដែលប្តឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ ១០៨ ចុះថ្ងៃទី ២៣-៥-៧៧ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

- បានឃើញបណ្តឹងសាទុក្ខលេខ ១៩១ ចុះថ្ងៃទី ០៥-០៦-១៩៧៧ របស់ឈ្មោះ ឃុំសុវណ្ណរិទ្ធ ដែលប្តឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ ១០៨ ចុះថ្ងៃទី២៣-៥-៧៧ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

- បានឃើញសារណាចុះថ្ងៃទី០១-៧-១៩៧៧ របស់ឈ្មោះឃុំសុវណ្ណរិទ្ធ

- បានឃើញសារណាចុះថ្ងៃទី១៨-៥-១៩៧៧ របស់ឈ្មោះ ចុង គី

- បានឃើញសារណាតបចុះថ្ងៃទី១៨-១១-៧៧ របស់ឈ្មោះ ចុង គី

- បានឃើញសារណាតបចុះថ្ងៃទី៣០-១០-៧៧ របស់ឈ្មោះ ឃុំសុវណ្ណរិទ្ធ

- បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

- បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការអមតុលាការកំពូលថា :

១- បណ្តឹងសាទុក្ខរបស់ឈ្មោះចុង គី និង ឃុំ សុវណ្ណរិទ្ធ ធ្វើឡើងក្នុងកំណត់ច្បាប់ គប្បីលើកយកមកពិនិត្យពិចារណា ។

២- តំកល់សាលដីកាព្រហ្មទណ្ឌលេខ ១០៨ ចុះថ្ងៃទី២៣-៥-៧៧ របស់ សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

- បានស្តាប់ចម្លើយអះអាងរបស់អ្នកស្រី ចុង គី "ម្ចាស់បណ្តឹងសាទុក្ខ" នាពេលសវនាការថា: ហេតុដែលនាងខ្ញុំប្តឹងសាទុក្ខនោះ ព្រោះថាក្នុងរឿងនេះកូនរបស់ខ្លួន បាននៅបំរើការគីដើមចោទនោះអស់រយៈច្រើនឆ្នាំទាំងមិនទាន់គ្រប់អាយុ ដោយធ្វើបាបកូនខ្ញុំគ្រប់បែបយ៉ាង តាមតែគេចង់ធ្វើ សូមតុលាការកំពូលរកយុត្តិធម៌ផង ។

- បានស្តាប់ចម្លើយអះអាងរបស់ចុងចាប់ចោទឈ្មោះ ចាន់ រតនា នាពេលសវនាការថា: នាងខ្ញុំពុំមានកំហុសអ្វីទាំងអស់ គឺគ្រួសារដើមចោទធ្វើបាបខ្ញុំ ដោយប្រើឱ្យធ្វើការគ្រប់យ៉ាង សូមអស់លោកបល់និងសុំរកយុត្តិធម៌ ។

- បានស្តាប់ចម្លើយអះអាងរបស់ឈ្មោះឃុំ សុវណ្ណរិទ្ធ "ម្ចាស់បណ្តឹងសាទុក្ខ" និងជាដើមបណ្តឹងរដ្ឋប្បវេណី នាពេលសវនាការថា: ខ្ញុំបាទប្តឹងនេះ គឺចង់ឱ្យអ្នកដែលជាអាណាព្យាបាលទទួលស្គាល់ថា កូនរបស់គាត់ទទួលខុសត្រូវចំពោះមុខច្បាប់ខ្លះ និងស្គាល់ថា កូនគាត់ខូចអឺរ ឬយ៉ាងណា? ព្រោះគាត់កាន់ជើងកូនពេក ។ ការដែលចោទខ្លួនផ្តេសផ្តាសដូច្នេះ សូមឱ្យនៅរៀបចំពាក្យសម្តី ទើបអស់ចិត្ត បើសិនចុងចោទមិនព្រមទទួលកំហុសរបស់ខ្លួន ខ្ញុំសូមទាមទារដូចតុលាការថ្នាក់ក្រោមសំរេច ។

- បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់តំណាងមហាអយ្យការអមតុលាការកំពូលថា : ពុំមានអ្វីបន្ថែមទៀតទេ សូមរក្សាការសន្និដ្ឋានរបស់ខ្លួនដដែលដដែល ។

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍ .

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់ជនជាប់ចោទ អ្នកទទួលខុសត្រូវខាងរដ្ឋប្បវេណី និង ដើមបណ្តឹងរដ្ឋប្បវេណី .
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់

## តុ លា កា រ កំ ពូ ល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ១៧៨ ចុះថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ១៩៨៧ របស់ឈ្មោះ ឡុង គី និង បណ្តឹងសាទុក្ខលេខ ១៩១ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ១៩៨៧ របស់ឈ្មោះ ឃុំ សុវណ្ណរិទ្ធ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ឈ្មោះចាន់ រតនា ហៅស្រី អាង បានថ្លែងសារភាពថា កាលពីថ្ងៃទី៣ - ៥ - ៨៥ ខ្លួនបានយកកន្ទុយភ្ញាទីដែលកំពុងឆេះចោលចូលទៅក្នុងផ្ទះតាមបង្អួចបន្ទប់ដេក របស់អ្នកស្រីចាន់ ចន្ទ័សោភា និងប្រុសពេទ្យឃុំ សុវណ្ណរិទ្ធ បណ្តាលឱ្យឆេះ ពូក និង ខ្នើយ ដោយខ្លួនមានគំនុំជាមួយស្រីសោភាដែលជាកូនមកហើយប្រាកដមែន ។ ដូច្នេះ ឈ្មោះនេះមានពិរុទ្ធពីបទ បង្ករអោយមានអគ្គីភ័យដោយចេតនា ។

- យល់ឃើញថា ការដែលឈ្មោះឃុំ សុវណ្ណរិទ្ធ ស្នើឲ្យតុលាការផ្តន្ទាទោស ពន្ធនាគារចំពោះជនជាប់ចោទនោះ តុលាការកំពូលពុំអាចពិចារណាបានទេ ហើយ ការដែលអ្នកទទួលខុសត្រូវខាងរដ្ឋប្បវេណី លើកឡើងអំពីការដែលដើមបណ្តឹងរដ្ឋប្បវេណី ទាមទារប្តូរកូនរបស់ខ្លួននោះ ជារឿងដែលអង្គសេចក្តីមួយផ្សេងទៀត ដែលតុលាការថ្នាក់ក្រោមត្រូវពិចារណា ។

- យល់ឃើញ សាលដីកាព្រហ្មទណ្ឌលេខ ១០៨ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ ១៩៨៧ របស់ សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីខាងនេះ មានលក្ខណៈត្រឹមត្រូវទាំង ទំរង់ និងគតិច្បាប់ហើយ ។

## ដោ យ ហេ តុ ដូ ច្នេះ

វិនិច្ឆ័យសេចក្តីចំពោះមុខជនជាប់ចោទអ្នកទទួល
ខុសត្រូវខាងរដ្ឋប្បវេណី និង ដើមបណ្តឹង
រដ្ឋប្បវេណី

១ - ទទួលបណ្តឹងសាទុក្ខលេខ ១៩១ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ ១៩៨៧

របស់ឈ្មោះសុំ សុវណ្ណារិទ្ធ និង បណ្ដឹងសាទុក្ខលេខ ១៧៨ ចុះថ្ងៃទី២៣ ខែឧសភាឆ្នាំ ១៩៩៧ របស់ឈ្មោះយុង គឺ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយទាស់ខុសនឹងនីតិច្បាប់ ។

២ - តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ១០៨ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣ - សាលដីកានេះប្រកាសនៅសវនាការជាសាធារណៈ

នៅថ្ងៃទី ៣០ ខែឧសភា ឆ្នាំ ២០០១ ។